# សវនាការភស្តុតាងក្នុងករណី០០២ : ថ្ងៃទីពីរ និងថ្ងៃទីបី

*ដោយ រ៉េនខល ឌីហ្វាល់កូ*

*ថ្ងៃទី១៧-១៨ ខែមករា ឆ្នាំ២០១២*

*កែសម្រួលដោយ ដា ដល្លា*

*កាលពីថ្ងៃទី១៧ និង១៨ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ផ្តើមសវនាការលើភស្តុតាងដែលមានរយៈពេលពេញមួយសប្តាហ៍ ។ សវនាការនេះនឹងផ្តល់ឱកាសឲ្យគ្រប់ភាគីទាំងអស់ពិភាក្សាគ្នាអំពីបញ្ហាដាក់បញ្ចូលឯកសារដែលជាប្រភពនៃភស្តុតាង ។*

## *ការសង្ខេបដំណើរការសវនាការថ្ងៃទី១៧ ខែមករា*

*កាលពីថ្ងៃទី១៧ ខែមករា គ្រប់ភាគីទាំងអស់បានបន្តពិភាក្សាអំពីឯកសារភស្តុតាង ជាពិសេសពិភាក្សាអំពីតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ពេញមួយថ្ងៃ ភាគីការពារក្តីទាំងអស់ ជាពិសេសភាគីការពារក្តីរបស់ នួន ជា នៅតែរក្សាជំហររបស់ខ្លួនដដែល ដោយទាមទាឲ្យអង្គជំនុំជម្រះកោះហៅលោក ឆាំង យុ ចូលមកក្នុងសវនាការដើម្បីបង្ហាញពីការយកឯកសារមកប្រើប្រាស់នៅក្នុងតុលាការ ។*

*ព្រះរាជអាជ្ញាបានជំទាស់ដោយបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នអព្យាក្រឹត្យនិងស្វែងរកការពិត ។ លើសពីនេះទៅទៀត នរណាក៏ដោយឲ្យតែអាចបញ្ជាក់ថាឯកសារនោះជាឯកសារពិត គឺអាចទទួលយកបានទាំងអស់ ដោយមិនចាំបាច់តែមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។ ព្រះរាជអាជ្ញាបានអះអាងទៀតថា ក្រោមក្រមអន្តរជាតិស្តីអំពីភស្តុតាង មិនចាំបាច់បង្កើតទម្រង់ការពិនិត្យមើលគ្រប់ឯកសារទាំងអស់ទេ មុននឹងយកមកធ្វើជាភស្តុតាងនោះ ហើយការធ្វើបែបនេះក៏មានការលំបាកដែរ ព្រោះអាយុកាលរបស់ឯកសារមានវ័យជាងសាបសិបឆ្នាំមកហើយ ។*

*ព្រះរាជអាជ្ញាបានជំទាស់ទៀតថា ឯកសារណាមួយដែលទាក់ទងជាមួយបក្សកុម្មុយនីស្តកម្ពុជា ជាពិសេសទាក់ទងទៅនឹង អៀង សារី ដែលរៀបរាប់អំពីការជម្លៀសប្រជាជនចេញពីទីក្រុង ក្នុងឆ្នាំ១៩៧៥ គឺជាឯកសារដែលអាចប្រើការបានទាំងអស់ ហើយព័ត៌មានទាំងនោះសុទ្ធតែអះអាងដោយភាគីខាងក្រៅដែរ ។ លើសពីនេះទៅទៀត ព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញថា អត្ថបទដែលរៀបរាប់ពីការសម្លាប់និងការអត់ឃ្លាន ដោយសរសេរឡើងតាមរយៈការសម្ភាសន៍ពីជនភៀសខ្លួនខ្មែរ ដែល*

ទៅនៅប្រទេសថៃគួរតែដាក់បញ្ចូលដែរ ព្រោះជនភៀសខ្លួនទាំងនោះ បានផ្តល់នូវភស្តុតាងទាក់ទងនឹងសហខក្រិដ្ឋកម្មរួម ដែលជនជាប់ចោទទាំងបីនេះ គឺជាបុគ្គលនៅក្នុងសហខក្រិដ្ឋកម្មរួមនេះដែរ ។ ភាគីព្រះរាជអាជ្ញាបានបញ្ជាក់ដែរថា អៀង សារី បានធ្លាប់ប្រានចោលមិនទទួលស្គាល់អត្ថបទទាំងនោះ ដោយបញ្ជាក់ថា មានតែខក្រិដ្ឋជនដែលមិនស្មោះត្រង់ប៉ុណ្ណោះ ដែលបានគេចខ្លួនពីរបបកម្ពុជាប្រជាធិបតេយ្យ ។

ព្រះរាជអាជ្ញាបានកត់សម្គាល់ថា អត្ថបទទាំងនេះមានការពាក់ព័ន្ធគ្នា ព្រោះឯកសារនោះបានបញ្ជាក់ថា ជនជាប់ចោទត្រូវបានផ្តល់ភស្តុតាងយ៉ាងច្បាស់ក្រឡែតថា បានដឹងពីការអត់ឃ្លាននិងដឹងពូពីការកាប់សម្លាប់ តែមិនបានចាត់វិធានការណ៍ណាមួយដើម្បីដោះស្រាយទៅនឹងបញ្ហាទាំងនោះទេ ។

ចំពោះភាគីការពារក្តីរបស់ អៀង សារី បានបន្តជំទាស់នឹងការដាក់បញ្ចូលអត្ថបទដែលបានដកស្រង់សម្តីរបស់ជនជាប់ចោទ អៀង សារី ព្រមទាំងអត្ថបទផ្សេងទៀតដោយផ្តល់ជូនតាមរយៈសារអេឡិចត្រូនិច ដែលផ្ញើពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងអត្ថបទដែលសរសេរដោយអ្នកសារព័ត៌មានអេលីហ្សាប៊ែត បេ៊កឃើ ។ មេធាវីប្រឹក្សារបស់ អៀង សារី បានអះអាងថា ឯកសារទាំងនោះមិនមានលក្ខណៈច្បាស់លាស់ ហើយការដកស្រង់សម្តីរបស់ អៀង សារី ក៏មិនត្រឹមត្រូវដែរដោយសារតែសារព័ត៌មានទាំងនោះមានភាពលំអៀង ដូចជាសារព័ត៌មានវ៉ាស៊ីនតោនប៉ុស្តិ៍ និងញូយ៉កថៃមស៍ជាដើម សារព័ត៌មានទាំងនេះគួរតែមិនត្រូវរាប់បញ្ចូលទេ ។ មេធាវីប្រឹក្សារបស់ ខៀវ សំផន បានបន្ថែមទៅនឹងការជំទាស់ខាងលើ ដោយដកស្រង់អត្ថបទសារព័ត៌មានមួយដែលបានចុះខុសកាលបរិច្ឆេទនៃការធ្វើសម្ភាសជាមួយ ខៀវ សំផន ។

ព្រះរាជអាជ្ញាបានឆ្លើយតបថា ការអះអាងរបស់មេធាវីការពារក្តីអំពីការដកស្រង់ខុសដោយបញ្ជាក់ថា ក្នុងករណីនេះចៅក្រមអាចយកមកពិចារណាអំពីកាលៈទេសៈដែលមេដឹកនាំខ្មែរក្រហមបានធ្វើសេចក្តីថ្លែងការណ៍ ។

## សវនាការថ្ងៃទី១៨

## ការបកស្រាយរបស់ព្រះរាជអាជ្ញា

ភាគីព្រះរាជអាជ្ញាចាប់ផ្តើមរៀបរាប់ពីការបញ្ចូលឯកសារ ដោយបកស្រាយអំពីសារៈសំខាន់នៃឯកសារដែលបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជា ដែលឯកសារទាំងនោះបានផ្តល់នូវទិដ្ឋភាពរួមនៃកិច្ចការរបស់បក្សក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ដំបូង ព្រះរាជអាជ្ញាបានពិភាក្សាអំពីទស្សនាវដ្ដីទង់បដិវត្តន៍ និងកូនសៀវភៅយុវជនបដិវត្តន៍ ។ ព្រះរាជអាជ្ញាបានរៀបរាប់ខ្លះៗអំពីសណ្ឋានឯកសារដោយបញ្ជាក់ថា គម្របសៀវភៅមានពណ៌ក្រហម ហើយថា ចំនួនទង់ជាតិបានផ្លាស់ប្ដូរក្នុងឆ្នាំ១៩៧៧ ។ អ្វីដែលបានរៀបរាប់ដោយព្រះរាជអាជ្ញានេះគឺ ដើម្បីឆ្លើយតបទៅនឹងអ្វីដែល នួន ជា បានអះអាងថា សៀវភៅទាំងនោះមិនមានភាពត្រឹមត្រូវ និង ខុសទម្រង់ដើម ។ ព្រះរាជអាជ្ញាបានបញ្ជាក់ថា នួន ជា មានការភាន់ច្រឡំនៅពេលដែលគាត់អះអាងថា ក្រោយឆ្នាំ១៩៧៥ ទស្សនាវដ្ដីទង់បដិវត្តន៍ត្រូវបានប្ដូរទៅពណ៌ក្រហមវិញនោះ ។ ព្រះរាជអាជ្ញាបាន បញ្ជាក់ទៀតថា ពាក្យ«ទស្សនាវដ្ដីទង់បដិវត្តន៍»មាននៅលើសៀវភៅទាំងអស់ ហើយទង់ជាតិនៅលើ គម្របកូនសៀវភៅនីមួយៗមានពណ៌ក្រហម ដូចអ្វីដែល នួន ជា បានបញ្ជាក់ដែរ តែចំណងជើងនៅ តែមានឈ្មោះថា «ទស្សនាវដ្ដីទង់បដិវត្តន៍»ដដែល ។

បន្ទាប់មក ព្រះរាជអាជ្ញាបានបកស្រាយអំពីខ្លឹមសារមួយចំនួននៅក្នុងទស្សនាវដ្ដីនោះ ។ ជា បឋមព្រះរាជអាជ្ញាបានបញ្ជាក់ថា លេខរបស់សៀវភៅនីមួយៗមានភាពស៊ីគ្នាទៅនឹងកាលបរិច្ឆេទ តាម លំដាប់លំដោយពេលវេលា ។ កូនសៀវភៅភាគច្រើនចុះផ្សាយអត្ថបទជាច្រើន តែលេខខ្លះមានអត្ថបទ វែងតែមួយប៉ុណ្ណោះ ជាពិសេសអត្ថបទដែលជាប្រសាសន៍របស់មេដឹកនាំបក្សកម្ពុជាប្រជាធិបតេយ្យ ។ ទស្សនាវដ្ដីទាំងនោះ គឺជាការបោះពុម្ពផ្សាយ«ផ្លូវការ»របស់បក្សកុម្មុយនីស្ដកម្ពុជា និងបានបោះពុម្ព ផ្សាយរៀងរាល់ខែ ។

ព្រះរាជអាជ្ញាបន្ត និងបានបង្ហាញអំពីទស្សនាវដ្ដីទង់បដិវត្តន៍នៅលើអេក្រង់កុំព្យូទ័រ ដោយបាន ចង្អុលបង្ហាញថា ខ្លឹមសារពិតមួយចំនួនមាននៅក្នុងឯកសារទាំងអស់នោះ ។ ព្រះរាជអាជ្ញាបានបញ្ជាក់ថា ទស្សនាវដ្ដីជាច្រើនត្រូវបានបញ្ជាក់ដោយ នួន ជា ខ្លួនឯងផ្ទាល់ផងដែរក្នុងអំឡុងពេលធ្វើការជំទាស់ទៅ នឹងឯកសារថតចម្លង ។

ព្រះរាជអាជ្ញាបានលើកយកទស្សនាវដ្ដីយុវជនបដិវត្តន៍មកបង្ហាញ ដោយបញ្ជាក់ថា មានតែ សមាជិកបក្សកុម្មុយនីស្ដកម្ពុជាប៉ុណ្ណោះ ទើបអាចទទួលបាននូវទស្សនាវដ្ដីដែលបោះពុម្ពផ្សាយដោយ បក្សកុម្មុយនីស្ដកម្ពុជានេះ ។ ព្រះរាជអាជ្ញាបានសង្កេតឃើញថា សាក្សី ឡុង នរិន្ទ ដែលបានធ្វើសក្ខី កម្មកាលពីខែមុន ក៏ធ្លាប់បានឃើញទស្សនាវដ្ដីយុវជនបដិវត្តន៍ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិប តេយ្យដែរ ។

ព្រះរាជអាជ្ញាបានឲ្យដឹងទៀតថា ទស្សនាវដ្ដីយុវជនបដិវត្តន៍ និងទស្សនាវដ្ដីទង់បដិវត្តន៍សុទ្ធតែ បោះពុម្ពផ្សាយដោយក្រសួងឃោសនាការរបស់បក្សកុម្មុយនីស្ដកម្ពុជា ព្រះរាជអាជ្ញាក៏បានដកស្រង់ពី អត្ថបទសម្ភាសន៍មួយចំនួនដែលធ្វើសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ក៏បានអះអាងស្រដៀងគ្នា

ថា ទស្សនាវដ្ដីទាំងពីរប្រភេទនោះត្រូវបានបោះពុម្ពផ្សាយដោយក្រសួងឃោសនាការ ។ ព្រះរាជអាជ្ញាបានបន្តថា នួន ជា ផ្ទាល់ធ្លាប់និយាយថា គាត់ និង ប៉ុល ពត ជាអ្នកទទួលខុសត្រូវសរសេរទស្សនាវដ្ដីទង់បដិវត្តន៍ ។ ព្រះរាជអាជ្ញាបានគូសបញ្ជាក់ថា អង្គជំនុំជម្រះក៏បានដាក់បញ្ចូលលេខមួយចំនួនអំពីទស្សនាវដ្ដីនៅក្នុងករណី០០១ដែរ ហើយអតីតជាប់ចោទនៅក្នុងករណីនោះ កាំង ហ្គេចអ៊ាវ ហៅ ឌុច ក៏មិនជំទាស់ទៅនឹងការដាក់បញ្ចូលឯកសារនោះដែរ ។

ព្រះរាជអាជ្ញាបានអះអាងថា អំពីសៀវភៅដែលបោះពុម្ពផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជា និងឯកសារដែលដាក់បញ្ចូលដោយព្រះរាជអាជ្ញាមានលក្ខណៈស៊ីគ្នា ព្រមទាំងមានលក្ខណៈត្រឹមត្រូវតាមព្រឹត្តិការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ព្រះរាជអាជ្ញាក៏បានលើក ឧទាហរណ៍មួយចំនួនអំពីឯកសារនិងព្រឹត្តិការណ៍នោះដែរ ។

ព្រះរាជអាជ្ញាធ្វើការសរុបដោយបញ្ជាក់ថា នេះមានភាព«ច្បាស់លាស់»ថា ឯកសារដើមរបស់ខ្មែរក្រហមផ្ទុកព័ត៌មានគ្រប់គ្រាន់ដែលអាចទុកចិត្តបាន ហើយព្រះរាជអាជ្ញាក៏បានដាក់បញ្ចូលជាភ័ស្តុតាងហើយដែរ ។

## ភាគីដើមបណ្ដឹងរដ្ឋប្បវេណីបកស្រាយអំពីការជំទាស់របស់ភាគីការពារក្ដី

ភាគីដើមបណ្ដឹងរដ្ឋប្បវេណី បានឡើងធ្វើការបកស្រាយទាក់ទងទៅនឹងការជំទាស់អំពីភ័ស្តុតាង ។ មេធាវីរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានគាំទ្រទាំងស្រុងទៅនឹងអ្វី ដែលព្រះរាជអាជ្ញាបានបកស្រាយពេលនេះភាគីដើមបណ្ដឹងរដ្ឋប្បវេណី បានជូនយោបល់បន្ថែមទាក់ទងទៅនឹងឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយបញ្ជាក់ថា ឯកសារបោះពុម្ពផ្សាយមួយចំនួនផ្ទុកព័ត៌មានសំខាន់ ហើយឯកសារទាំងនោះត្រូវបានចែកជូនដល់សមាជិកបក្សទាំងអស់ ឯកសារមួយចំនួនក៏បានរៀបរាប់អំពីសេចក្ដីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា និងមេដឹកនាំខ្មែរក្រហមទៅកាន់កម្មាភិបាលនៅតាមមូលដ្ឋានដើម្បីឲ្យកម្មាភិបាលទាំងនោះអាចធ្វើកិច្ចការប្រកបដោយប្រសិទ្ធភាព ។ បន្ទាប់មក ភាគីដើមបណ្ដឹងរដ្ឋប្បវេណី បានផ្ដល់យោបល់អំពីហេតុផលដែលឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តទាំងអស់គួរតែដាក់បញ្ចូលទៅក្នុងអង្គសវនាការ ។

ក្រោយពីភាគីដើមបណ្ដឹងរដ្ឋប្បវេណីនិយាយចប់ មេធាវីភាគីដើមបណ្ដឹងរដ្ឋប្បវេណីទីពីរបានក្រោកឈរ និងបានស្នើទៅអង្គជំនុំជម្រះសុំបង្ហាញពណ៌របស់គម្របសៀវភៅទង់បដិវត្តន៍ ដែលភាគីដើមបណ្ដឹងរដ្ឋប្បវេណីរូបនោះ ទើបតែរកឃើញថ្មីៗនៅលើគេហទំព័ររបស់អង្គការយូណេស្កូ ។

អង្គជំនុំជម្រះបានជំទាស់ទៅនឹងសំណើនេះដោយបញ្ជាក់ថា ភាគីនីមួយៗត្រូវប្រើប្រាស់ពេលវេលាឲ្យបានត្រឹមត្រូវ ហើយអង្គជំនុំជម្រះបានបញ្ជាក់ថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចបង្ហាញរូបភាពនៅលើអេក្រង់កុំព្យូទ័របានទេ។

## អង្គជំនុំជម្រះផ្ដល់យោបល់ទៅលើបញ្ហាសាក្សីមជ្ឈមណ្ឌលឯកសារកម្ពុជា

ក្រោយពីសម្រាករួច អង្គជំនុំជម្រះបានផ្ដល់យោបល់ទាក់ទងទៅនឹងការទាមទារឲ្យលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាចូលមកបំភ្លឺនៅអង្គសវនាការ។ ប្រធានអង្គជំនុំជម្រះ និល ណុន បានបញ្ជាក់ថា អង្គជំនុំជម្រះមានការពេញចិត្ត បើមានអ្នកតំណាងណាមួយមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា មកធ្វើការបំភ្លឺនៅសវនាការ ហើយលោកចៅក្រមបានបញ្ជាក់ទៀតថា បើសិនជាអង្គជំនុំជម្រះចង់លឺសក្ខីកម្មរបស់លោក ឆាំង យុ អង្គជំនុំជម្រះនឹងធ្វើការអញ្ជើញលោកក្នុងនាមជាសាក្សីក្នុងករណីនេះ។

## មេធាវីការពារក្ដីរបស់ នួន ជា ឡើងនិយាយ

បន្ដមកទៀត ក្រុមការពារក្ដីរបស់ នួន ជា បានក្រោកឈរនិងអះអាងថា ភាគីការពារក្ដីមានបំណងនឹងអញ្ជើញសាក្សីមួយរូប មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលអាចបង្ហាញអំពីភាពខុសគ្នាក្នុងឯកសាររបស់បក្សកុម្មុយនីស្ដកម្ពុជា។ មេធាវីការពារក្ដីបានបញ្ជាក់ថា លោក ឆាំង យុ បានបង្ហាញនូវឆន្ទះរបស់ខ្លួនក្នុងសារព័ត៌មានភ្នំពេញប៉ុស្ដិ៍ថា គាត់រក្សាសិទ្ធិមិនចូលមកបង្ហាញទេ ត្រង់ចំណុចនេះអ្នកតំណាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអាចនឹងមកបង្ហាញបាន។

មេធាវីការពារក្ដីនៅតែបន្ដជំទាស់អំពីភាពស្របច្បាប់របស់ឯកសារមួយចំនួន ដែលបានយកមកបង្ហាញនៅក្នុងអង្គសវនាការនេះ។ មេធាវីការពារក្ដីបានបញ្ជាក់ថា ឯកសារមួយចំនួននៅក្នុងសំណុំរឿងគឺជាឯកសារខុសច្បាប់ ហេតុដូចនេះមិនអាចដាក់បញ្ចូលក្នុងសវនាការបានទេ។

មេធាវីប្រឹក្សាអន្ដរជាតិរបស់ នួន ជា ក៏បានបញ្ជាក់ទាក់ទងទៅនឹងឯកសារភស្ដុតាងថា ទោះបីជាឯកសារជាច្រើនត្រូវបានដាក់បញ្ចូលនៅក្នុងសវនាការដោយព្រះរាជអាជ្ញារួចហើយ ទោះជាព្រះរាជអាជ្ញាបញ្ជាក់ថា ឯកសារនោះ«មានការចាប់អារម្មណ៍»ក៏ដោយ ក៏ឯកសារបោះពុម្ពផ្សាយភាគច្រើនត្រូវបានបោះពុម្ពផ្សាយជាងបួនខែ ក្រោយថ្ងៃរំដោះទីក្រុងភ្នំពេញថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ មេធាវីការពារក្ដីបានបញ្ជាក់ទៀតថា កាលពីឆ្នាំមុន ព្រះរាជអាជ្ញាបានដាក់បញ្ចូលឯកសារ

ជាច្រើនដែលមិនទាក់ទងទៅនឹងប្រធានបទ ដែលបានលើកមកនិយាយនៅក្នុងដំណាក់កាលករណី០០២ នេះទេ ។

## មេធាវីការពារក្តីរបស់ អៀង សារី ឡើងនិយាយ

មេធាវីអន្តរជាតិរបស់ អៀង សារី ចាប់ផ្តើមជំទាស់ជាថ្មីម្តងទៀតដោយបញ្ជាក់ថា ព្រះរាជអាជ្ញា«កំពុងតែធ្វើការបង្វាញ»ទាក់ទងទៅនឹងភាពពិតនៃឯកសារដែលកំពុងតែមានបញ្ហា ។ ក្រុមការពារក្តីបានបញ្ជាក់ថា ព្រះរាជអាជ្ញាត្រូវតែ«ផ្តល់ភស្តុតាង» ដោយបញ្ជាក់ពីការពន្យល់នៃឯកសារនីមួយៗថាបានបញ្ជាក់នូវភាពពិតរួចហើយតាមរយៈការធ្វើសក្ខីកម្មរបស់អ្នកជំនាញណាមួយ ។

មេធាវីការពារក្តីបានបញ្ជាក់ថា នៅក្នុងករណី០០១ អង្គជំនុំជម្រះបានបញ្ជាក់ពីភាពពិតរបស់ឯកសារជាក់លាក់អំឡុងពេលនៃដំណើរការសវនាការរួចហើយ ហើយមេធាវីការពារក្តីបានបញ្ជាក់ថា នេះគឺជាការប្លន់យកឱកាសពីភាគីការពារក្តីក្នុងការជំទាស់ទៅនឹងឯកសារនោះ ។

មេធាវីការពារក្តីបានបញ្ជាក់ថា ហេតុការណ៍ដែលបានវិនិច្ឆ័យនៅក្នុងករណី០០១មិនអាចយកមកប្រើប្រាស់នៅក្នុងករណី០០២ដោយគ្មានការបញ្ជាក់ឲ្យច្បាស់បានទេ ។ ភាគីការពារក្តីបានបន្តថា នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅក្នុងករណី ដូលីក អង្គជំនុំជម្រះតម្រូវឲ្យបញ្ជាក់ឲ្យច្បាស់ពីភាពពិតរបស់ភស្តុតាង ដែលបានថតជាកាសែស្សែតមុននឹងយកមកប្រើនៅក្នុងតុលាការនេះ ។

ក្រុមមេធាវីការពារក្តីបានអះអាងទៀតថា ព្រះរាជអាជ្ញាបានស្នើរកការដាក់បញ្ចូលរាល់ឯកសារទាំងអស់ទាក់ទងទៅនឹងករណី០០២ ព្រោះព្រះរាជអាជ្ញាមិនមានជំនឿសោះថា សវនាការ០០២នឹងចាប់ផ្តើមនោះ ។ មេធាវីរបស់ អៀង សារី បានបញ្ជាក់ថា ចំណុចនេះបង្កើតឲ្យមានគ្រោះថ្នាក់ដល់ដំណើរការសវនាការដែលពឹងទៅលើឯកសារដែលមានលក្ខណៈសង្ស័យជ្រុលពេក ខណៈពេលដែលមានការប្រើប្រាស់សក្ខីកម្មដោយផ្ទាល់ ។

ទាក់ទងទៅនឹងដំណើរការបញ្ជាក់ពីភាពពិត មេធាវីការពារក្តីបានអះអាងថា បើសិនជាឯកសារណាមួយមានសញ្ញាឡូហ្គោជាក់លាក់ ឬឈ្មោះនៅលើឯកសារនោះ ចំណុចនេះមិនមែនបញ្ជាក់ពីភាពពិតរបស់ឯកសារទេ លុះត្រាតែព្រះរាជអាជ្ញាអាចបញ្ជាក់តាមរយៈសាក្សីថា តើឯកសារនេះត្រូវបានបញ្ជាក់ដោយរបៀបណា ដូច្នេះឯកសារទាំងនេះគួរតែត្រូវបានដកចេញ ។

ភាគីការពារក្តីបានអះអាងថា ព្រះរាជអាជ្ញាត្រូវតែផ្តល់បញ្ជីភស្តុតាងឲ្យបានច្រើនទាក់ទងទៅនឹងករណី០០២ នៅដំណាក់កាលដំបូង ។ មេធាវីការពារក្តីមិនត្រូវរំពឹងថានឹងពិនិត្យមើលតាមរយៈសំណុំ

ឯកសារជាច្រើនដើម្បីរកមើលឯកសារណាមួយដែលពាក់ព័ន្ធ ហើយមេធាវីការពារក្ដីក៏បានជម្រុញឲ្យព្រះរាជអាជ្ញាឲ្យចាំថា «មិនត្រូវឲ្យគំនរចំបើងយើងទេ តែត្រូវតែផ្ដល់ម្ជុលឲ្យយើង» ។

## មេធាវីរបស់ ខៀវ សំផន ឡើងបកស្រាយ

មេធាវីរបស់ ខៀវ សំផន បានអះអាងថា បើគ្មានសក្ខីកម្មគាំទ្រច្បាស់លាស់ទេ ឯកសារនោះមិនត្រូវយកមកផ្ទៀងផ្ទាត់ ហើយគួរតែដកចេញ ។ តាមរយៈកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ មេធាវីការពារក្ដីបានបញ្ជាក់ថា ឯកសារទាំងនេះ ត្រូវបានរកឃើញក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរំលំទៅ ហើយឯកសារនោះមិនមានភាពពិតទេ ។

មេធាវីការពារក្ដីបានបញ្ជាក់ដោយសាមញ្ញថាដោយសារតែនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រគល់ឯកសារជូនមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ១៩៩៥ ដែលឯកសារនោះបញ្ជាក់អំពីកំណត់ហេតុកិច្ចប្រជុំរវាងបក្សកុម្មុយនីស្ដកម្ពុជានិងគណៈប្រតិភូបរទេស ហើយឯកសារនេះមិនមានភាពពេញលេញពិតប្រាកដទេ ។ មេធាវីការពារក្ដីបានបញ្ជាក់ថា ឯកសារដើមនីមួយៗត្រូវតែពិនិត្យមើលឲ្យបានច្បាស់ថាតើឯកសារនេះរកឃើញដោយរបៀបណា? តើឯកសារនោះ ជាឯកសារថតចម្លងឬឯកសារដើម? តើឯកសារនោះជាឯកសារថតចម្លងចេញពីឯកសារថតចម្លងឬយ៉ាងណា?

មេធាវីការពារក្ដីបានអះអាងថា ចំពោះការថែរក្សាឯកសារបណ្ណសារទាំងនោះ តើស្ថាប័នណាមួយមើលថែទាំឯកសារទាំងនោះ ហើយទាមទាឲ្យមានការពិនិត្យមើលឯកសារនោះឲ្យបានត្រឹមត្រូវ ។

ទាក់ទងទៅនឹងឯកសាររបស់បក្សកុម្មុយនីស្ដកម្ពុជា មេធាវីការពារក្ដីរបស់ ខៀវ សំផន បានអះអាងដោយសាមញ្ញថា ដោយសារតែឃ្លា«ចក្រពត្តិអាមេរិក»មានឈ្មោះនៅក្នុងឯកសារនោះដែរនោះដូច្នេះមិនត្រូវធ្វើការបញ្ជាក់ឲ្យច្បាស់ពីឯកសារនោះទេ ព្រោះពាក្យនេះត្រូវបានប្រើជាទូទៅកាលពីអំឡុងពេលនោះ ។

មេធាវីការពារក្ដីបានសន្និដ្ឋានដោយស្នើថា ភាពអាចពឹងពាក់បានរបស់ឯកសារដែលអះអាងដោយព្រះរាជអាជ្ញា គឺមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបញ្ជាក់ឲ្យច្បាស់ទេ ដូច្នេះឯកសារនោះត្រូវតែធ្វើការពិនិត្យមើលជាមុនសិនមុននឹងដាក់ឯកសារនោះបញ្ចូល ។

## ការសង្កេតមើលរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងការដាក់សំណើរបស់ នួន ជា

នៅពេលរសៀល អង្គជំនុំជម្រះបានបន្តសវនាការរបស់ខ្លួនដោយបញ្ជាក់ថា មិនគួរមានការភាន់ច្រឡំអំពីតម្រូវការរបស់វិធានផ្ទៃក្នុង៨៧(៣) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ដែល

វិធាននេះ ចែងអំពីការដាក់ឯកសារនេះជាផ្លូវការនៅចំពោះមុខអង្គជំនុំជម្រះ និងហេតុផលក្នុងការមិនបញ្ចូលភ័ស្តុតាងដែលបានស្នើ ។ បន្ទាប់មកលោកចៅក្រម និល ណុន បានប្រគល់នាទីនេះជូនទៅចៅក្រម ហ្វេនហ្ស ។ ចៅក្រម ហ្វេនហ្ស ក៏បានបញ្ជាក់អំពីបញ្ហានៃការបកប្រែកាលពីពេលព្រឹក និងបានបន្តថា អង្គជំនុំជម្រះនឹងទទួលយកការផ្តល់ជូនរបស់ព្រះរាជអាជ្ញាចំពោះឯកសារដាក់លាក់ណាមួយដែលមានការពាក់ព័ន្ធនឹងអាចដាក់បញ្ចូលបាន ។

## ព្រះរាជអាជ្ញាឆ្លើយតបទៅនឹងបញ្ហាភ័ស្តុតាង

ក្រោយមក ព្រះរាជអាជ្ញាត្រូវបានផ្តល់ឱកាសក្នុងការឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីការពារក្តីកាលពីព្រឹកមិញ ។ ព្រះរាជអាជ្ញាបានបញ្ជាក់ថា ខ្លួនមិនបាន«ធ្វើការបង្ហាញ»ទេនៅពេលដែលកំពុងពិភាក្សាពីបញ្ហានេះកាលពីលើកមុន តែខ្លួនបានបង្ហាញដល់អង្គជំនុំជម្រះ អំពីទិដ្ឋភាពរួមជម្រុញឲ្យមានភាពជឿជាក់របស់ឯកសារទាំងនេះ ។

ដោយសារតែឯកសារដែលភាគីការពារក្តីបានអះអាងគឺជាឯកសារមិនស្របច្បាប់ ព្រះរាជអាជ្ញាបានបញ្ជាក់ថា ឯកសារទាំងនោះមានភាពច្បាស់ជាងនៅពេលមើលតាមកម្មវិធីកុំព្យូទ័រ Zylab ចំណែកឯការមើលតាមអេក្រង់កុំព្យូទ័ររបស់តុលាការមិនសូវច្បាស់ទេ ។ តែឯកសារទាំងអស់នេះត្រូវបានបកប្រែទៅជាភាសាបារាំងនិងអង់គ្លេស ព្រមទាំងបានបញ្ជាក់ពីភាពស្របច្បាប់រួចហើយ ហើយបើសិនជាមានឃ្លាណាមួយមិនមានលក្ខណៈត្រឹមត្រូវ ឃ្លានោះក៏មិនជះឥទ្ធិពលដល់ការដាក់បញ្ចូលរបស់ឯកសារដទៃទៀតដែរ ។

ទាក់ទងទៅនឹងកំណត់ហេតុអង្គប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជាដែលកំពុងមានបញ្ហា ព្រះរាជអាជ្ញាបានអះអាងថា ឯកសារនោះធ្វើឲ្យយើងអាចយល់ដឹងអំពីរចនាសម្ព័ន្ធបញ្ជា និងនយោបាយរបស់ខ្មែរក្រហមដែលគួរតែពិចារណាក្នុងការដាក់បញ្ចូលក្នុងករណី០០២ ។ ក្រោយមកព្រះរាជអាជ្ញាបានផ្តល់ជូនឯកសារពិតទាំងនេះ និងពន្យល់អំពីរបៀបដែលឯកសារទាំងនេះអាចយកមកប្រើប្រាស់ដើម្បីយល់ព័ត៌មានដែលទាក់ទងទៅនឹងដំណើការដំបូងនៃករណី០០២ ។ ក្នុងអំឡុងពេលនៃដំណើរការសវនាការនេះ ព្រះរាជអាជ្ញាបានបញ្ជាក់ថា ខៀវ សំផន ផ្ទាល់ធ្លាប់បានអះអាងពីមុនថា គាត់មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេ ហើយគាត់បានប្រើប្រាស់កំណត់ហេតុកិច្ចប្រជុំជាភ័ស្តុតាង ។ ព្រះរាជអាជ្ញាអះអាងថា ការធ្វើបែបនេះ ខៀវ សំផន អាចបញ្ជាក់ពីភាពត្រឹមត្រូវរបស់ឯកសារនោះបាន ។

ព្រះរាជអាជ្ញាក៏បានជំទាស់ទៀតដែរថា ផ្អែកទៅលើប្រធានបទដែលបានពិភាក្សានៅក្នុងគណៈអចិន្ត្រៃយ៍ និងបញ្ជីឈ្មោះអ្នកដែលបានចូលរួម រួមទាំងឈ្មោះជនជាប់ចោទក្នុងករណី០០២ផងនោះ កំណត់ហេតុនោះត្រូវបានប៉ាន់ប្រមាណថាជាឯកសារពិត ។ ព្រះរាជអាជ្ញាបានបន្តទៀតថា កំណត់ហេតុនេះ អាចនឹងបញ្ជាក់ឲ្យកាន់តែច្បាស់តាមរយៈការធ្វើសក្ខីកម្មជាច្រើននាក់ ហើយសាក្សីមិនស្គាល់ឈ្មោះម្នាក់ នឹងចូលមកធ្វើសក្ខីកម្មដើម្បីបញ្ជាក់ពីភាពច្បាស់លាស់នៃឯកសាររបស់គណៈអចិន្ត្រៃយ៍ ។

ព្រះរាជអាជ្ញាបានបញ្ជាក់ថា កំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍គួរតែមានភាពពិត ព្រោះរាល់សេចក្ដីសម្រេចជាច្រើនដែលបានសម្រេចនៅក្នុងកិច្ចប្រជុំនោះបានចូលជាធរមានផងដែរ ជាក់ស្ដែងដូចជាផែនការសាងសង់ព្រលានយន្តហោះនៅកំពង់ឆ្នាំងជាដើម ។ ការស្ថាបនាព្រលានយន្តហោះនេះបានចាប់ដំណើរការភ្លាមក្រោយពីកិច្ចប្រជុំ ហើយសាក្សីដែលធ្លាប់ធ្វើការនៅព្រលានយន្តហោះនោះផ្ទាល់នឹងឡើងមកនិយាយ ។

ក្រោយមក ព្រះរាជអាជ្ញាបានបន្ថែមព័ត៌មានផ្សេងទៀត ហើយព្រះរាជអាជ្ញានឹងធ្វើការបញ្ជាក់អំពីភាពច្បាស់លាស់របស់កំណត់កិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ។ ព្រះរាជអាជ្ញាក៏បានផ្ដល់នូវទិដ្ឋភាពនៃប្រធានបទដែលបានរៀបរាប់ទូទាំងកិច្ចប្រជុំនោះ ។ ក្នុងអំឡុងពេលនៃការដាក់បញ្ចូលឯកសារនេះ ព្រះរាជអាជ្ញាបានបញ្ជាក់ថា កាលពីដំបូងបក្សកុម្មុយនីស្តកម្ពុជាផ្ដោតទៅលើវិស័យកសិកម្ម តែក្រោយមកកំណត់ហេតុអង្គប្រជុំផ្ដោតទៅលើការកំចាត់សត្រូវទៅវិញ ។

ព្រះរាជអាជ្ញាបានសន្និដ្ឋានដោយបញ្ជាក់ថា ភាពដែលអាចពឹងពាក់បានរបស់ឯកសារដែលមានបញ្ហាទាំងនេះគឺជាឯកសារចាំបាច់ដែលអាចដាក់ចូលជាភស្តុតាងបាន ។

## ***ភាគីដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងភាគីការពារក្ដី***

ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានផ្ដល់ឱកាសដើម្បីឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមការពារក្ដី ។ មេធាវីរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ការបន្តដាក់បញ្ចូលភស្តុតាងទាក់ទងទៅនឹងបញ្ហាបច្ចេកទេសមិនមែនជាតួនាទីរបស់ភាគីការពារក្ដីទេ ។ ដូច្នេះ ភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើ "សេចក្ដីថ្លែងការណ៍ទូទៅ" ទាក់ទងទៅនឹងការជំទាស់នេះដែរ ។ ភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានអះអាងថា ភាគីការពារក្ដីបានព្យាយាមយកមកពិភាក្សាសាកមើលអំពីតម្លៃនៃប្រភេទភស្តុតាងផ្សេងៗ ជាជាងពិភាក្សាអំពីការដាក់បញ្ចូលភស្តុតាងទាំងអស់នោះ ។ ភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តថា ការពិភាក្សារបស់ភាគីការពារក្ដីនោះនៅមានលក្ខណៈក្មេងខ្ចីណាស់ ។ ភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ចប់សេចក្ដី

ឆ្លើយតបរបស់ខ្លួនដោយរំពឹកទៅអង្គជំនុំជម្រះអំពី ការដាក់បញ្ចូលភ័ស្តុតាងរបស់អង្គជំនុំជម្រះ គឺអាចដាក់បញ្ចូលបាន ។

## ការតវ៉ាបន្ថែមទៀតដោយក្រុម នួន ជា

ក្រោយពីសម្រាករួច មេធាវីការពារក្តីរបស់ នួន ជា ត្រូវបានផ្តល់ឱកាសដើម្បីនិយាយ និងចោទសួរអំពីឯកសារដើម ។ មេធាវីការពារក្តីទាមទារឲ្យអ្នកតំណាងម្នាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាមកធ្វើសក្ខីកម្មដើម្បីបង្ហាញដល់អង្គជំនុំជម្រះអំពីឯកសារ ។ បន្ទាប់មក មេធាវីអន្តរជាតិរបស់ នួន ជា បានក្រោកឡើងហើយជម្រាបទៅអង្គជំនុំជម្រះថា នួន ជា កំពុងតែដេកលក់នៅក្នុងបន្ទប់រង់ចាំ និងបានបញ្ជាក់ថា នួន ជា កំពុងតែខ្សោយជាខ្លាំង គាត់បានសុំសិទ្ធនៅក្រៅបន្ទប់សវនាការ ។ មេធាវីបានបន្ថែមទៀតថា នួន ជា បានគេងលក់ស្ទើរពេញដំណើរការថ្ងៃនេះ ។

មេធាវីការពារក្តីបានបញ្ជាក់ជំហររបស់ខ្លួនថា រាល់ឯកសារដែលយកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់គួរតែដកចេញទាំងអស់ បើសិនជាលោក ឆាំង យុ មិនចូលខ្លួនមកធ្វើសក្ខីកម្មទេ ។ មេធាវីការពារក្តីបាននិយាយម្តងទៀតទៅកាន់ព្រះរាជអាជ្ញាថា ឲ្យបញ្ជាក់ឲ្យច្បាស់ថា តើឯកសារណាមួយដែលយកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

មេធាវីការពារក្តីបានជំទាស់ជាថ្មីម្តងទៀតទៅនឹងឯកសារជាច្រើន ដែលខ្លួនគិតថាមិនមានការពាក់ព័ន្ធទៅនឹងដំណាក់កាលដំបូងនៃសវនាការ០០២ ។ ដើម្បីបញ្ជាក់ឲ្យច្បាស់ពីចំណុចនេះមេធាវីប្រឹក្សាបានផ្តល់ឧទាហរណ៍នូវឯកសារមួយចំនួនដែលខ្លួនជឿថាមិនមានការពាក់ព័ន្ធ ។ មេធាវី បានបញ្ចប់ដោយអះអាងថា ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាតដាក់ឯកសារដែលមិនពាក់ព័ន្ធទាំងអស់នេះ ធ្វើជាភ័ស្តុតាងនៅតុលាការនេះ គឺជាការគ្រោះថ្នាក់នៃ«ការលិចលង់ក្នុងបឹងនៃឯកសារមិនពាក់ព័ន្ធ» ។

## មេធាវី អៀង សារី តវ៉ាបន្ថែមទៀត

មេធាវីការពារក្តីរបស់ អៀង សារី យល់ស្របជាមួយមេធាវីការពារក្តីរបស់ នួន ជា ទាក់ទងទៅនឹងការដាក់បញ្ចូលឯកសារច្រើនហួសពេកធ្វើជាភ័ស្តុតាង ព្រមទាំងបានអះអាងថា គោលបំណងរបស់ព្រះរាជអាជ្ញាក្នុងការនាំយកឯកសារទាំងអស់នេះ គឺជាបំណងក្នុងការធ្វើឲ្យឯកសារទាំងអស់នោះអាចយកមកបានសម្រាប់ធ្វើជាភ័ស្តុតាង ដើម្បីឲ្យខ្លួនអាចអះអាងអំពីការចោទប្រកាន់ដែលបាននិយាយនៅក្នុងដីការដំណោះស្រាយ ។

មេធាវីការពារក្តីរបស់ អៀង សារី បានជំទាស់ដោយបញ្ជាក់ថា ខ្លួនមិនជំទាស់ទៅនឹងភ័ស្តុតាងនេះទេ តែមេធាវីការពារក្តីជំទាស់ទៅនឹងឯកសារដែលព្រះរាជអាជ្ញាចង់ប្រើប្រាស់ដោយមិនបានបញ្ជាក់ថាមានភាពជឿជាក់បាន ។

ក្រុមការពារក្តីរបស់ អៀង សារី បានបន្តការអះអាងរបស់ខ្លួនទៀតថា ជាឯកសារ«ទទួលបានដោយការធ្វើទារុណកម្ម» ។ មេធាវីការពារក្តីរបស់ អៀង សារី បានបញ្ជាក់ថា រាល់ភ័ស្តុតាងទាំងអស់ដែលធ្វើឡើងដោយការធ្វើទារុណកម្មត្រូវតែដកចេញ ។ ទាក់ទងទៅនឹងសាទូរលេខរបស់បក្សកុម្មុយនីស្តកម្ពុជា មេធាវីការពារក្តីបានអះអាងថា ឈ្មោះបុគ្គលណាមួយដែលមាននៅក្នុងទូរលេខ សរបញ្ជាក់ឲ្យឃើញថា ឈ្មោះនោះពិតជាទទួលបានឯកសារនោះ ។ តែមេធាវីការពារក្តីក៏បានបញ្ជាក់ដែរថា ទោះជាទូរលេខជាច្រើនមានឈ្មោះ អៀង សារី ក៏មិនមានន័យថា អៀង សារី ទទួលបានឯកសារទាំងនោះដែរ ។

ក្រោយមក មេធាវីការពារក្តីបានលើកយកទូរលេខមួយមកធ្វើជាឧទាហរណ៍ដោយទូរលេខនោះមានឈ្មោះ “បងញឹម” និង “បងចាន់” ហើយបានជំទាស់ទៅនឹងការដាក់បញ្ចូលឯកសារប្រភេទនេះបើសិនជាមិនមានមូលដ្ឋានគ្រឹះនៃឯកសារនេះទេនោះ ។

## មេធាវីការពារក្តីរបស់ ខៀវ សំផន បានតវ៉ាបន្ថែម

មេធាវីការពារក្តីរបស់ ខៀវ សំផន បានក្រោកឡើងតវ៉ាទៅនឹងការដាក់បញ្ចូលឯកសារដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មេធាវីបានបញ្ជាក់ទៀតថា ខ្លួនមិនមានសិទ្ធសម្រេចពីឯកសារណាមួយទេ តែព្រះរាជអាជ្ញាមិនបានបញ្ជាក់ឲ្យច្បាស់ពីភាពពិតរបស់ឯកសារ និងភាពអាចទទួលយកបានរបស់ឯកសារណាមួយ មុននឹងដាក់បញ្ចូលទៅក្នុងតុលាការទេ ។

មេធាវីការពារក្តីបានបញ្ជាក់ទៀតថា បើសិនជាស្ថានប័នណាមួយអះអាងខ្លួនឯងថា អព្យាក្រឹត្យដូច្នេះឯកសារដែលទទួលបានអាចទុកចិត្តបាន ។ តែឯកសារមកពីស្ថានប័នដែលមានភាពលំអៀងត្រូវតែពិនិត្យមើលឲ្យបានច្បាស់លាស់ ដូចជាឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាជាដើម ។

## ព្រះរាជអាជ្ញាធ្វើការឆ្លើយតប

ព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងការអះអាងរបស់ភាគីការពារក្តី ដោយបានផ្តល់ខ្លឹមសារទូទៅនៃវិធានភ័ស្តុតាងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ទាក់ទងទៅនឹងអ្វីដែលមេធាវីការពារក្តីអះអាងថា ឯកសារបានមកតាមរយៈការធ្វើទារុណកម្ម ព្រះរាជអាជ្ញាបានយល់ស្របដោយបញ្ជាក់ថា ឯកសារនេះមិនអាចយកមកប្រើប្រាស់បានទេ តែព្រះរាជអាជ្ញាបានអះអាងថា ភស្តុតាងទាំងនេះអាចយកមកបង្ហាញថា ការអះអាងនោះ គឺធ្វើឡើងក្រោមការគំរាមកំហែង ។ ព្រះរាជអាជ្ញាបានលើកឡើងថា ក្រោមអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ការអះអាងណាមួយដែលធ្វើឡើងក្រោមការបង្ខិតបង្ខំពិតជាមិនអាចទទួលយកធ្វើជាភស្តុតាងបានទេ ហើយត្រូវតែដកចេញដូចអ្វីដែលមេធាវីការពារក្តីបានអះអាងដូច្នេះដែរ ។ តែអនុសញ្ញានោះ ក៏មិនបានហាមឃាត់ការប្រើប្រាស់ចម្លើយសារភាពដែលធ្វើឡើងក្រោមការបង្ខិតបង្ខំដោយខ្មែរក្រហមទេ ។

ព្រះរាជអាជ្ញាបានអះអាងទៀតថា ទម្ងន់នៃភស្តុតាងដូចជាទូរលេខ គឺមិនមែនឋិតនៅក្រោមការពិចារណារបស់អង្គជំនុំជម្រះទេ ការពិចារណាបែបនេះ អាចយកមកអនុវត្តនៅទីបញ្ចប់នៃដំណើរការសវនការ ក្រោយពីភស្តុតាងទាំងអស់ត្រូវបានបង្ហាញរួចហើយ ។ ពេលនោះ ចៅក្រម និល ណុន បានសួរទៅព្រះរាជអាជ្ញាថា តើត្រូវការពេលវេលាប៉ុន្មានទៀតដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្តី ។ ព្រះរាជអាជ្ញាបានឆ្លើយថា ខ្លួនត្រូវការពេលប្រមាណជាកន្លះម៉ោងទៀត ។ លោកចៅក្រម និល ណុន បានប្រកាសថា សវនាការបញ្ចប់នៅពេលនេះ រួចបន្តទៀតនៅព្រឹកស្អែក ។ ក្រោយពីអង្គជំនុំជម្រះប្រកាសឈប់សម្រាប់ថ្ងៃនេះមេធាវីអន្តរជាតិរបស់ នួន ជា ឈ្មោះ អេនឌ្រូ អ៊ីនូហ្វី បានក្រោកឈរដោយបញ្ជាក់ថា ក្រុមមេធាវីរបស់ នួន ជា “មានភាពរីករាយយ៉ាងខ្លាំង” ដែលចៅក្រម ហ្សេនហ្វ បានប្រែក្លាយខ្លួនពីចៅក្រមបម្រុង មកជាចៅក្រមដែលអាចអង្គុយក្នុងអង្គសវនាការ ដោយគ្មាន“ការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា” ។ អេនឌ្រូ អ៊ីនូហ្វី បានបន្តទៀតថា “ស្ថានភាពនេះ គឺផ្ទុយគ្នាស្រឡះទៅនឹងស្ថានភាពដែលបានកើតឡើងក្នុងអង្គសវនាការមុនៗ” ហើយ អេនឌ្រូ អ៊ីនូហ្វី បានផ្តល់ការគាំទ្រដល់សហចៅក្រមអន្តរជាតិ ដែលត្រូវបានរារាំងមិនឲ្យចូលកាន់តំណែងដោយក្រុមប្រឹក្សាកំពូលនៃអង្គចៅក្រមកម្ពុជា ។ ចៅក្រម និល ណុន បានឆ្លើយតបទៅមេធាវី អេនឌ្រូ អ៊ីនូហ្វី ថា ចៅក្រម ហ្សេនហ្វ និងចូលមកជំនួសចៅក្រម ខាត់វ្រាយត៍ នៅពេលណាដែលលោកស្រីមិនមានវត្តមាន ។ អង្គសវនាការបានបញ្ចប់សម្រាប់ថ្ងៃនេះ និងបន្តនៅថ្ងៃស្អែកទៀត ។

**- ចប់ -**